**សម្រាប់ការចុះផ្សាយបន្ទាន់**

HUMAN RIGHTS WATCH

www.hrw.org

# កម្ពុជា ៖ រដ្ឋាភិបាលធ្វើយុទ្ធនាការបង្ខំឱ្យចុះចូលគណបក្សកាន់អំណាច

(ញូយក ថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០០៨) អង្គការឃ្លាំមើលសិទ្ធិមនុស្សបាននិយាយនៅថ្ងៃនេះថា ការចោទប្រកាន់ពីបទព្រហ្មទណ្ឌដោយហេតុផលនយោបាយ ប្រឆាំងយ៉ាងហោចណាស់នឹងមន្ត្រីគណបក្សប្រឆាំងចំនួនបីរូប គឺជាផ្នែកមួយនៃយុទ្ធនាការរបស់គណបក្សកាន់អំណាចបំណងធ្វើឱ្យគូប្រជែងខាងនយោបាយ ចុះខ្សោយមុនការបោះឆ្នោតជាតិក្នុងខែកក្កដា ឆ្នាំ២០០៨ ។

នៅសប្តាហ៍មុននេះ អាជ្ញាធរបានចាប់ខ្លួន ទូត សារ៉ន ជាមន្ត្រីមួយរូបរបស់គណបក្ស សម រង្ស៊ី និងស្វែងរកចាប់ខ្លួនយ៉ាងហោចណាស់មន្ត្រីគណបក្ស សម រង្ស៊ី ពីររូបផ្សេងទៀត ។ អង្គការឃ្លាំមើលសិទ្ធិមនុស្សបារម្ភថា មន្ត្រីគណបក្ស សម រង្ស៊ី ថែមទៀតអាចប្រឈមមុខនឹងការចាប់ខ្លួនក្នុងពេលឆាប់ៗនេះផងដែរ ។

លោក ប្រាត អាដាំ នាយកអង្គការឃ្លាំមើលសិទ្ធិមនុស្សប្រចាំទ្វីបអាស៊ី បានមានប្រសាសន៍ថា "ការចាប់ខ្លួនគួរឱ្យសង្ស័យនៃមន្ត្រីប្រឆាំងក្នុងពេលច្រើនខែមុនការបោះឆ្នោត គួរតែដាក់កណ្តឹងរោទិ៍ប្រកាសឱ្យដឹងជាសញ្ញា" ។ "យុទ្ធ-សាស្ត្របំបែកបំបាក់ដើម្បីគ្រប់គ្រង គឺជាឧបាយកលល្បីឈ្មោះរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ដើម្បីបង្ក្រាបអ្នកប្រឆាំងរបស់ខ្លួន" ។

នៅថ្ងៃទី ១៣ ខែមីនា លោក ហ៊ុន សែន អនុប្រធាននៃគណបក្សប្រជាជនកម្ពុជាដែលកំពុងកាន់អំណាច់ផងដែរនោះ បានថ្លែងសុន្ទរកថាវាយប្រហារគណបក្ស សម រង្ស៊ី ថាជា "គណបក្សផ្តាច់ការ" និងថ្លែងដោយគ្មានភស្តុតាងថា គណបក្ស សម រង្ស៊ី បានបំភិតបំភ័យអតីតសមាជិកគណបក្ស សម រង្ស៊ី ដែលបានចុះចូលគណបក្សប្រជាជនកម្ពុជា ។ លោក ហ៊ុន សែន បានអះអាងថា មន្ត្រីគណបក្ស សម រង្ស៊ី ក្នុងខេត្តកំពង់ធំបានឃុំខ្លួនសកម្មជនគណបក្សមួយរូបដោយបង្ខំ ដើម្បីព្យាយាមបង្ការសកម្មជនរូបនេះពីការចុះចូលជាមួយគណបក្សប្រជាជនកម្ពុជា ។

ក្នុងកំឡុងសុន្ទរកថានោះ លោក ហ៊ុន សែន បានប្រកាសថា ការស៊ើបអង្កេតអំពីបញ្ហាឃុំឃាំងខ្លួននោះ គួរតែដឹកនាំដោយលោក សុខ ផេង អតីតអ្នកតំណាងរាស្ត្រគណបក្ស សម រង្ស៊ី ប្រចាំខេត្តកំពង់ធំ ដែលបានចុះចូលជាមួយគណបក្សប្រជាជនកម្ពុជានៅខែមុន និងត្រូវបានផ្តល់រង្វាន់ ដោយការតែងតាំងជាទីប្រឹក្សារបស់រដ្ឋាភិបាល ។

នៅថ្ងៃទី ១៨ ខែមីនា នគរបាលបានចាប់ខ្លួនលោក ទួត សារ៉ន ប្រធានក្រុមប្រឹក្សាឃុំរបស់គណបក្ស សម រង្ស៊ី ក្នុងខេត្តកំពង់ធំ និង បានប្រកាសថាពួកគេកំពុងតែមានគម្រោងចាប់ពីររូបផ្សេងទៀត នៃសហសេវិករបស់គាត់ក្នុងគណបក្សនេះ ។ បន្ទាប់ពីនគរបាលបានឃុំឃាំងខ្លួនលោក ទួត សារ៉ន រយៈពេលមួយថ្ងៃកន្លះមក លោកត្រូវបានបញ្ជូនខ្លួនទៅតុលាការ ជាទីកន្លែងដែលគេចោទលោកពីបទផ្សំគំនិតក្នុងការឃុំឃាំងសកម្មជនគណបក្សដោយខុសច្បាប់ ហើយគេក៏បានបញ្ជូនលោកទៅឃុំឃាំងក្នុងពន្ធនាគារខេត្តកំពង់ធំរង់ចាំការជំរះក្តី ។

លោក អាដាំ មានប្រសាសន៍ថា "គណបក្សប្រជាជនកម្ពុជាបានរៀបចំការចោទប្រកាន់បទព្រហ្មទណ្ឌប្រឆាំងលោក ទួត សារ៉ន ហើយនគរបាលនិងតុលាការកំពុងធ្វើអ្វី១ឱ្យល្អបំផុត តាមបទបញ្ជាថ្នាក់លើ " ។ "គ្មានការប្រាថ្នាឱ្យមានប្រព័ន្ធយុត្តិធម៌ឯករាជ្យទាល់តែសោះ ខណៈពេលដែលនាយករដ្ឋមន្ត្រីចោទប្រកាន់គណបក្សប្រឆាំងជាសាធារណៈអំពីការប្រព្រឹត្តបទឧក្រិដ្ឋ ហើយតែងតាំងមនុស្សផ្ទាល់ខ្លួនឯងជាទីប្រឹក្សារដ្ឋាភិបាលមួយរូបដោយគ្មានយុត្តាធិការប្រតិបត្តិច្បាប់ទាល់តែសោះ ឱ្យធ្វើការងារ "ស៊ើបអង្កេត" ។

អង្គការឃ្លាំមើលសិទ្ធិមនុស្សជឿថា ការចោទប្រកាន់បទព្រហ្មទណ្ឌគឺជាផ្នែកនៃយុទ្ធនាការរដ្ឋាភិបាលដែលមានការរៀបចំ ដើម្បីបង្ខំសមាជិកគណបក្ស សម សង្ស៊ីឱ្យចុះចូលគណបក្សប្រជាជនកម្ពុជា និងដាក់ទោសសមាជិកទាំងឡាយណាដែលមិនព្រមធ្វើតាមក្នុងបំណងបំបែកបំបាក់ និងធ្វើឱ្យគណបក្សប្រឆាំងចុះខ្សោយមុនការបោះឆ្នោតជាតិ ។

ក្នុងពេលប៉ុន្មានខែថ្មី១នេះ លោក ហ៊ុន សែន បានផ្តល់ជាសាធារណៈនូវប្រាក់បៀវត្សរសម្រាប់តំណែងទីប្រឹក្សារដ្ឋាភិបាលចំពោះមន្ត្រីជាន់ខ្ពស់គណបក្ស សម រង្ស៊ី ណាដែលចុះចូលគណបក្សប្រជាជនកម្ពុជា ។ លោក ហ៊ុន សែន បានបរិហារអ្នករិះគន់ដែលចង្អុលបង្ហាញថា លោកកំពុងតែទាញយកប្រយោជន៍នយោបាយផ្ទាល់ខ្លួនដោយប្រើប្រាក់កាសរបស់រដ្ឋាភិបាលមិនត្រឹមត្រូវ ដើម្បីចំណាយចំពោះការអូសទាញបែបនេះ ។ គណបក្សរបស់លោក ហ៊ុន សែន បានព្យាយាមផងដែរដើម្បីបំភិតបំភ័យនិងបង្ខិតបង្ខំសមាជិកគណបក្ស សម រង្ស៊ីឱ្យប្តូរភក្តីភាព ។

គណបកប្រជាជនកម្ពុជា មានប្រវត្តិយករដ្ឋាភិបាលជាឈ្នាន់ ដើម្បីរៀបចំបំបែកបំបាក់ផ្ទៃក្នុងគណបក្សនយោបាយដទៃទៀត មានជាអាទិ៍ការរលាយបែកបាក់ជាយថាហេតុនៃគណបក្សប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនាក្នុងទសវត្សរ៍១៩៩០ ហើយនៅពេលថ្មី១នេះ ការបែកបាក់ដ៏ធំនៅក្នុងដៃគូរដ្ឋាភិបាលចម្រុះរបស់គណបក្សប្រជាជនកម្ពុជាគឺគណបក្សហ៊្វុនស៊ិនប៉ិច ។ គណបក្ស សម រង្ស៊ី បានប្រឈមមុខនឹងការគាបសង្កត់ឱ្យបែកជាពីរស្រដៀងគ្នាក្នុងអតីតកាល ពីសំណាក់គណបក្សប្រជាជនកម្ពុជា ។

គណបក្សប្រជាជនកម្ពុជា បានប្រើប្រាស់ការចោទប្រកាន់ពីបទព្រហ្មទណ្ឌតាមបែបនយោបាយផងដែរ ប្រឆាំងនឹងអ្នកប្រជែងខាងនយោបាយរបស់ខ្លួនអស់ពេលជាយូរមកហើយ មានជាអាទិ៍ ការចាប់លោក ជៀម ចាន់នី តំណាង

រាស្ត្រគណបក្ស សម រង្ស៊ី ដាក់ពន្ធនាគាររយៈពេលមួយឆ្នាំ ដោយកាត់ទោសលោកក្នុងឆ្នាំ២០០៥ តាមបទចោទប្រកាន់គ្មានភស្តុតាងថាបានបង្កើតទ័ពឧទ្ទាម និងបានកាត់ទោសមេដឹកនាំគណបក្ស សម រង្ស៊ី ដោយគ្មានភស្តុតាងនៅឆ្នាំដដែលពីបទបរិហារកេរ្តិ៍មេដឹកនាំរដ្ឋាភិបាល ។

លោក អាដាំ មានប្រសាសន៍ថា "មានបែបផែនគំរូជាយូរមកហើយនៅប្រទេសកម្ពុជា ក្នុងការធ្វើទុក្ខទោសនិងបំភិតបំភ័យគណបក្សប្រឆាំងពីសំណាក់គណបក្សប្រជាជនកម្ពុជា" ។ "អ្នកការទូតនិងម្ចាស់ជំនួយគួរតែនិយាយឱ្យបានច្បាស់នៅពេលឥឡូវនេះ និងមិនត្រូវរង់ចាំរៀនសូត្រពីរបៀបរំលោភសិទ្ធិដោយរដ្ឋាភិបាលក្នុងរង្វង់ពេលនៃការបោះឆ្នោតនីមួយៗនោះឡើយ" ។